ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ...០៩០.........បទ.ប្រក..............

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ១២៦ បទ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ .-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍។

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៤២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩

ប្រការ ២.-

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម៖

- រៀបចំមុខងារ និងភារកិច្ចរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា
- រៀបចំមុខងារ និងភារកិច្ចរបស់ការិយាល័យនានានៃមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

ប្រការ ៣.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ការិយាល័យក្រោមឱវាទមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

## ជំពូកទី ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

ប្រការ ៤.-

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍លើការងារគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

ប្រការ ៥.-

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា មានមុខងារ និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទ និងសេវាថ្មីៗបន្ថែមទៀត ស្របតាមការវិវត្តនៃបច្ចេកវិទ្យាក្នុងវិស័យនេះ
- គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីសូហ្វវែរសម្រាប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ
- ប្រមូលរាល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា និងសេវាថ្មីៗបន្ថែមទៀតពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍ តាមរយៈការតភ្ជាប់បណ្ដាញផ្ទាល់ ឬតាមមធ្យោបាយបច្ចេកទេសសមស្របផ្សេងទៀត ជាមួយប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- គ្រប់គ្រង និងជំរុញការតភ្ជាប់បណ្ដាញរវាងប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ ដើម្បីសម្រួលចរាចរទិន្នន័យឆ្លងប្រព័ន្ធរវាងប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ធានាសុក្រឹតភាព សុវត្ថិភាព និងសន្តិសុខចំពោះទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាទាំងឡាយដែលបានប្រមូលពីប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ពិនិត្យ សិក្សា និងវិភាគលើទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីជាមូលដ្ឋានសម្រួលដល់ការកំណត់ពន្ធ និងអាករ និងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដែលកំណត់ដោយច្បាប់ និងដល់ការព្យាករណ៍ប្រភពចំណូល និងសក្ដានុពលសេដ្ឋកិច្ចក្នុងវិស័យទូរគមនាគមន៍
- ចូលរួមសហការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ សម្រាប់អភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបច្ចុប្បន្នភាពនៃទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាជូនដល់អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍
- ផ្ដាច់ចរាចរទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាខុសច្បាប់ ស្របតាមការណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- គ្រប់គ្រងការងាររដ្ឋបាលរបស់មជ្ឈមណ្ឌល
- រៀបចំផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ

- អនុវត្តការកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៦ .-**

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យប្រតិបត្តិការបណ្ដាញ
- ការិយាល័យគ្រប់គ្រង និងវិភាគទិន្នន័យ។

**ប្រការ ៧ .-**

ការិយាល័យនីមួយៗរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៣
## តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ

**ប្រការ ៨ .-**

ការិយាល័យរដ្ឋបាលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់មជ្ឈមណ្ឌល
- គ្រប់គ្រងចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់មជ្ឈមណ្ឌល
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់មជ្ឈមណ្ឌល
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងរបស់មជ្ឈមណ្ឌល
- សរុបរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់មជ្ឈមណ្ឌលប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលប្រគល់ជូន។

**ប្រការ ៩ .-**

ការិយាល័យប្រតិបត្តិការបណ្ដាញ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងជំរុញការតភ្ជាប់បណ្ដាញ រវាងប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ ដើម្បីសម្រួលចរាចរទិន្នន័យឆ្លងប្រព័ន្ធរវាងប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ប្រមូលរាល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា និងសេវាថ្មីៗបន្ថែមទៀតពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍ តាមរយៈការតភ្ជាប់បណ្ដាញផ្ទាល់ ឬតាមមធ្យោបាយបច្ចេកទេសសមស្របផ្សេងទៀត ជាមួយប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ផ្ដាច់ចរាចរទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាខុសច្បាប់ ស្របតាមការណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ចូលរួមសហការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ សម្រាប់អភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ

- អនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលប្រគល់ជូន។

**ប្រការ ១០.-**

ការិយាល័យគ្រប់គ្រង និងវិភាគទិន្នន័យ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទ និងសេវាថ្មីៗបន្ថែមទៀត ស្របតាមការវិវត្តនៃបច្ចេកវិទ្យាក្នុងវិស័យនេះ
- គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីសូហ្វវែរសម្រាប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ
- ធានាសុក្រឹតភាព សុវត្ថិភាព និងសន្តិសុខចំពោះទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាទាំងឡាយដែលបានប្រមូលពីប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- ពិនិត្យ សិក្សា និងវិភាគលើទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីជាមូលដ្ឋានសម្រួលដល់ការកំណត់ពន្ធ និងអាករ និងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដែលកំណត់ដោយច្បាប់ និងដល់ការព្យាករណ៍ប្រភពចំណូល និងសក្តានុពលសេដ្ឋកិច្ចក្នុងវិស័យទូរគមនាគមន៍
- ចូលរួមសហការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ សម្រាប់អភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលប្រគល់ជូន។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២.-**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និងគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ប្រាក់ សុខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត

  " ដើម្បីជូនជ្រាប "

- ដូចប្រការ ១២

  " ដើម្បីអនុវត្ត "

- រាជកិច្ច
- ឯកសារ កាលប្បវត្តិ